**មាត្រា ៣** : លក្ខខ័ណ្ឌក្នុងការសុំលេខទិដ្ឋាការៈ បញ្ជីការឱសថ ត្រូវកំណត់ដោយក្រសួងសុខាភិបាល ។

**មាត្រា ៤** : ឱសថដែលបានទទួលលេខទិដ្ឋាការ ឬ បញ្ជីការឱសថពីក្រសួងសុខាភិបាល ត្រូវបង់សោហ៊ុយតាម ការកំណត់របស់ក្រសួងសុខាភិបាល ។

**មាត្រា ៥** : ការត្រួតពិនិត្យការផ្តល់ និង ការដកហូតវិញនូវលេខទិដ្ឋាការៈ ឬ បញ្ជីការឱសថជាសមត្ថកិច្ចរបស់ ក្រសួងសុខាភិបាល ។

**មាត្រា ៦** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាពតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៨** : អនុក្រឹត្យនេះមានអានុភាពជាធរមានអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ — នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា — ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** — **ហ៊ុន សែន**

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៤៥ អនក្រ

## ស្តីពីនិយ័តភាពគណនេយ្យនៃប្រព័ន្ធអាកាសចរស៊ីវិល

**អាកាសចរស៊ីវិលកម្ពុជា ពីជំពូក ១១ មកជំពូក ១០**

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ១៩៩៣

- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ នស ចុះថ្ងៃទី ២៨ខែធ្នូ ឆ្នាំ ១៩៩៣

- បានឃើញអនុក្រឹត្យ លេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១** : អនុញ្ញាតអោយធ្វើនិយ័តកម្មឥណទាន ឆ្នាំ ១៩៩៤ របស់អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជាចំនួន ១៨០.០០០.០០០៛ ( មួយរយប៉ែតសិបលានរៀលគត់ ) ពី :

**ជំពូក ១១**

- ប្រភេទ ០១ : ចំណាយសំភារៈ និង គ្រប់គ្រងរដ្ឋបាល
- កថាខ័ណ្ឌ ១៤ : ចំណាយដោយឡែករបស់ផ្នែក
- វាក្យខ័ណ្ឌ ០១ : ឈ្នួលស្នាក់ការរដ្ឋបាល

**បញ្ចូលទៅក្នុងជំពូក ១០**

- ប្រការ ០២ : បៀវត្ស និង ប្រាក់បំណាច់បុគ្គលិក ក្របខ័ណ្ឌអចិន្ត្រៃយ៍
- កថាខ័ណ្ឌ ០៣ : ប្រាក់បំណាច់ផ្សេងៗ
- វាក្យខ័ណ្ឌ ០២ : ប្រាក់បំណាច់ម៉ោងបន្ថែម

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| --- | --- |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***